**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

## វេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាលើកទី៣

**ថ្ងៃទី ០២-០៣ ខែមិថុនា ឆ្នាំ២០១០**

**ឯកឧត្តម ឈឿង យ៉ាណារ៉ា** អគ្គលេខាធិការគណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជា នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (គ.ជ.ន/ក.អ.ក)

## ប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការ និងការអភិវឌ្ឍន៍ដោយផ្តោតលើលទ្ធផល

- *សូមគោរពឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ជាប្រធានវេទិកា*
- *លោកជំទាវ និងឯកឧត្តម ជាសហសេវិកក្នុងរាជរដ្ឋាភិបាល*
- *លោកជំទាវ ឯកឧត្តម ប្រធានប្រតិភូ លោកជំទាវ ឯកឧត្តម ឯកអគ្គរដ្ឋទូត និងតំណាងដៃគូអភិវឌ្ឍន៍*
- *លោកជំទាវ ឯកឧត្តម លោក លោកស្រី*

១- ខ្ញុំមានក្តីសោមនស្សរីករាយដើម្បីយកឱកាសនេះ សម្រាប់ធ្វើបទបង្ហាញស្តីពីកិច្ចខិតខំប្រឹងប្រែងរួមគ្នាក្នុងការគ្រប់គ្រងហិរញ្ញប្បទានសហប្រតិបត្តិការ ។ បទបង្ហាញរបស់ខ្ញុំនឹងផ្តោតជាសំខាន់ទៅលើបណ្តាបញ្ហាដែលពាក់ព័ន្ធនឹងប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការ ព្រោះសមាជិកភាគច្រើននៃវេទិកានេះ បានទទួលនិងបានអានរបាយការណ៍ប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការនៅកម្ពុជាឆ្នាំ២០១០ដែលជាឯកសារយោងសម្រាប់ពិភាក្សាអំពីនិន្នាកានៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ក្នុងរយៈពេល២-៣ឆ្នាំចុងក្រោយនេះ ។ លើពីនេះ កិច្ចប្រជុំនៃគណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍កាលពីថ្ងៃទី២៩ ខែមេសា ក៏បានពិភាក្សាលើរបាយការណ៍នេះដែរ ។

*លោកជំទាវ ឯកឧត្តម លោក លោកស្រី*

២- ទិសដៅកម្រិតគោលនយោបាយសម្រាប់គ្រប់គ្រងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍មានការវិវត្តន៍ជាច្រើនក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ។ ប៉ុន្តែ ទិសដៅកម្រិតគោលនយោបាយបច្ចុប្បន្នមានភាពច្បាស់លាស់ហើយបានផ្តោតជាសំខាន់ទៅលទ្ធផល ។ ខ្ញុំជឿជាក់ថាទិសដៅកម្រិតគោលនយោបាយមានភាពត្រឹមត្រូវព្រោះការរៀបចំគោលនយោបាយនេះបានផ្អែកលើបទពិសោធន៍កន្លងមករបស់កម្ពុជា និងការអនុវត្តន៍បានត្រឹម

ត្រូវ នូវការប្តេជ្ញានានាកម្រិតសកលស្របតាមបរិការណ៍កម្ពុជា ។ ក្នុងស្មារតីនេះ ខ្ញុំនឹងបកស្រាយអំពីគោលដៅសំខាន់១៤ សម្រាប់អនុវត្តក្នុងរយៈពេលខ្លី និងមធ្យម ហើយក៏ស្នើសុំការគាំទ្របន្តទៀតពីសំណាក់ភាគីពាក់ព័ន្ធទាំងអស់ ទាំងខាងរាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិល សម្រាប់អនុវត្តគោលដៅទាំងនេះ ។

៣- នៅពេលដែលទំហំហិរញ្ញប្បទានសហប្រតិបត្តិការបានកើនឡើងដល់ប្រមាណជាង ១.០០០លានដុល្លាអាមេរិកក្នុងមួយឆ្នាំ ទន្ទឹមនឹងពេលដែលយើងកំពុងអនុវត្តដើម្បីឈានទៅសម្រេចបណ្តាគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជានាឆ្នាំ២០១៥ យើងត្រូវផ្តោតការងាររបស់យើងជាសំខាន់ទៅលើលទ្ធផល ។ ទន្ទឹមនឹងនេះ យើងក៏បានយល់ដឹងច្បាស់លាស់ជាងមុន អំពីកិច្ចការដែលយើងត្រូវបន្តអនុវត្តមុខទៀត អំពីរបៀបធ្វើការរួមគ្នាដើម្បីឈានទៅសម្រេចលទ្ធផលដែលរំពឹងទុកទាំងនេះ ។

៤- បទពិសោធន៍របស់យើងកន្លងមក បានបង្ហាញអំពីទំនាក់ទំនងយ៉ាងជិតស្និទ្ធរវាងភាពដឹកនាំ និងសមត្ថភាព ដែលអាចជួយកសាងនិងពង្រឹងសមត្ថភាពសម្រាប់ការអនុវត្តន៍ ដើម្បីសម្រាប់ឈានទៅបង្កើនភាពជាម្ចាស់ ។ គឺក្នុងស្មារតីនេះហើយដែលសកម្មភាពអាទិភាពរបស់យើងនឹងផ្តោតលើ :

- ការអនុវត្តន៍កំណែទម្រង់ស្នូល ពិសេសកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងកំណែទម្រង់រដ្ឋបាលសាធារណៈ
- ការប្រើប្រាស់ប្រព័ន្ធជាតិ
- ការគាំទ្រពីដៃគូអភិវឌ្ឍន៍សម្រាប់អនុវត្តគំនិតផ្តួចផ្តើមនានាដើម្បីអភិវឌ្ឍសមត្ថភាពតាមវិស័យ
- បន្តធ្វើសុខដុមនីយកម្មនៃដំណើរការរៀបចំផែនការ និងថវិកា

៥- ការវិភាគរបស់ គ.ជ.ន/ក.អ.ក ជាមួយនឹងសក្ខីកម្មដទៃទៀត បានបង្ហាញថា ការប្រើប្រាស់អភិក្រមទូទាំងកម្មវិធី គឺមានភាពភាពសមស្របសម្រាប់បរិការណ៍កម្ពុជា ។ ការប្រកាន់យកជំហរបែបនេះគឺ ពុំមែនធ្វើឡើងតាមរបៀបទ្រឹស្តីវោហារសាស្ត្រ ដោយមិនឈរលើមូលដ្ឋានច្បាស់លាស់នោះឡើយ ។ ប៉ុន្តែ ផ្ទុយទៅវិញ យើងបានផ្អែកលើសក្ខីកម្ម និងស្ថានភាពជាក់ស្តែងរបស់កម្ពុជា ។ ខ្ញុំជឿជាក់ ហើយក៏ដូចជារបាយការណ៍ស្តីពីប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការនៅកម្ពុជាឆ្នាំ២០១០បានគូសបញ្ជាក់យ៉ាងច្បាស់លាស់ថា ប្រសិនបើយើងធ្វើការរួមគ្នា នោះយើងនឹងសម្រេចបានគោលដៅរួមជាច្រើន ។ ខ្ញុំសូមអនុញ្ញាតគូសបញ្ជាក់ដូចតទៅ :

៦- កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ឆ្នាំ២០១០បានបង្ហាញថា កម្ពុជាមានការគាំទ្រពីដៃគូអភិវឌ្ឍន៍ជាច្រើន ដែលរាជរដ្ឋាភិបាលសូមស្វាគមន៍ និងសូមវាយតម្លៃខ្ពស់ចំពោះការគាំទ្រទាំងនេះសម្រាប់កិច្ចអភិវឌ្ឍន៍កម្ពុជា ។ សក្ខីកម្មជាក់ស្តែងជាច្រើនបានបញ្ជាក់ថា ហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍន៍បានតម្រឹមទៅនឹងបណ្តាអាទិភាពរបស់កម្ពុជា ។ ប៉ុន្តែ ការគាំទ្រទាំងនេះមិនទាន់បានចូលរួមប្រកបដោយប្រសិទ្ធភាពសម្រាប់លើកកម្ពស់សមត្ថភាព និងពង្រឹងប្រព័ន្ធជាតិ ដែលទាំងនេះមានសារៈសំខាន់សម្រាប់ធានាកិច្ចអភិវឌ្ឍន៍ប្រកបដោយចីរភាពក្នុងរយៈពេលវែង ។ លើសពីនេះ ក៏បានបង្កើនបន្ទុកបន្ថែមក្នុងការគ្រប់គ្រងរបស់មន្ត្រីដែលជាសមភាគីខាងរាជរដ្ឋាភិបាល តាមរយៈការប្រើប្រាស់នីតិវិធីស្របគ្នាដែលទាមទារឱ្យចំណាយពេលវេលាជាច្រើន និងការ

បង្វែរការប្រើប្រាស់សមត្ថភាពរបស់រាជរដ្ឋាភិបាលទៅក្នុងការគ្រប់គ្រងគម្រោងវិញ ។ ក្នុងស្ថានភាពនេះ គោលការណ៍ «ភាពជាម្ចាស់»របស់រាជរដ្ឋាភិបាលមិនទាន់មានភាពរឹងមាំដូចការរំពឹងទុកនៅឡើយ ។

៧- បទពិសោធន៍របស់យើងបានបង្ហាញថា យើងអាចដោះស្រាយបញ្ហាទាំងនេះបាន ។ នៅពេលដែលដៃគូអភិវឌ្ឍន៍អាចធ្វើការដោយរលូនជាមួយគ្នា និងជាមួយរាជរដ្ឋាភិបាលនោះ យើងអាចចែករំលែកព័ត៌មានបានទូលំទូលាយ យើងអាចកាត់បន្ថយចំណាយប្រតិបត្តិការ យើងអាចប្រើប្រាស់សមត្ថភាពបានចំទិសដៅ ហើយភាពជាម្ចាស់ក៏អាចប្រើប្រាស់បានពេញលេញ ដើម្បីដឹកនាំភាគីពាក់ព័ន្ធទាំងអស់ឆ្ពោះទៅរកសម្រេចលទ្ធផលដែលរំពឹងទុក ។

៨- ការអនុវត្តន៍«អភិក្រមទូទាំងកម្មវិធី» គឺជាកាលានុវត្តភាពសម្រាប់ឆ្លុះបញ្ចាំងអំពីសេណារីយ៉ូ«ឈ្នះ-ឈ្នះ» សម្រាប់យើងទាំងអស់គ្នា ។ អភិក្រមនេះអាចទទួលយកគ្រប់ទម្រង់ការទាំងអស់នៃការអនុវត្តន៍ ហើយយើងអាចឈានទៅសម្រេចគោលដៅរួមទាំងអស់របស់យើង ។ យើងបង្កើនប្រសិទ្ធភាពការងារតាមរយៈកិច្ចសហការល្អប្រសើរតាមរយៈការរៀបចំផែនការរួមគ្នា ការពិនិត្យតាមដានរួមគ្នា និងការប្រើប្រាស់ប្រព័ន្ធរបាយ-ការណ៍រួមគ្នាតែមួយ ។ លើសពីនេះ យើងអាចជម្រុញប្រសិទ្ធភាពតាមរយៈការវាយតម្លៃរួមគ្នាអំពីសមត្ថភាពដើម្បីផ្តល់ការគាំទ្រដោយមានការសម្របសម្រួល សម្រាប់ធានាដល់ការអនុវត្តន៍កំណែទម្រង់សំខាន់ៗ និងការបង្កើតលក្ខខ័ណ្ឌសម្រាប់ពង្រឹងភាពដឹកនាំ និងគណនេយ្យភាពទ្វេទិសដោយផ្តោតលើលទ្ធផល ។

*លោកជំទាវ ឯកឧត្តម លោក លោកស្រី*

៩- សកម្មភាពទាំងឡាយដែលបានអនុវត្តនិងសមិទ្ធផលដែលសម្រេចបានចាប់តាំងពីឆ្នាំ២០០៩មក បានបង្ហាញអំពីទិសដៅដែលត្រូវបន្តអនុវត្ត ហើយយើងត្រូវមានគណនេយ្យភាពចំពោះលទ្ធផលដែលយើងបានអនុវត្ត ។ ដូច្នេះ យើងចាំបាច់ត្រូវពិនិត្យមើលអំពីបណ្តាគំនិតផ្តួចផ្តើមសំខាន់ដែលបានអនុវត្ត និងបណ្តាការងារដែលត្រូវបន្តអនុវត្ត ។

១០- ក្នុងរយៈពេល៥ឆ្នាំកន្លងមកនេះ សមត្ថភាពរបស់ គ.ជ.ន/ក.អ.ក ត្រូវបានពង្រឹង ។ ក្នុងឋានៈជាភ្នាក់ងាររាជរដ្ឋាភិបាល ដែលមានភារកិច្ចសម្របសម្រួលហិរញ្ញប្បទានសហប្រតិបត្តិការ យើងមានភាពរឹងមាំជាងមុន ខាងបុគ្គលិក ខាងសមត្ថភាព ខាងគោលនយោបាយ និងខាងយន្តការគាំទ្រ ។ លើសពីនេះ ក្នុងអំឡុងពេល៣ឆ្នាំចុងក្រោយ យើងបានជួយពង្រឹងសមត្ថភាពការងារដល់ក្រសួងនិងស្ថាប័ននៃរាជរដ្ឋាភិបាល ព្រមទាំងក្រុមការងារតាមវិស័យនិមួយៗ តាមរយៈការរៀបចំឱ្យមានបណ្តាញក្រុមការងារបច្ចេកទេស និងផ្តល់ការគាំទ្រហិរញ្ញប្បទានជាកញ្ចប់ថវិកា ។ យន្តការទាំងនេះ នឹងអាចជួយគាំទ្រផ្ទាល់ដល់ក្រុមការងារបច្ចេកទេស ហើយនេះគឺជាវិធីសាស្ត្រសម្របសម្រួលសម្រាប់ធានាថា ការគ្រប់គ្រងហិរញ្ញប្បទានសហប្រតិបត្តិការត្រូវបានអនុវត្ត ហើយសមត្ថភាពត្រូវបានបង្កើន ដើម្បីឈានទៅការអភិវឌ្ឍន៍ដោយផ្តោតលើលទ្ធផល ។ ស្ថាប័នរបស់ខ្ញុំនឹងរៀបចំឯកសារស្តីពីសំណើនេះ ក្នុងរយៈពេលប៉ុន្មានសប្តាហ៍ខាងមុខ ហើយខ្ញុំសង្ឃឹមថា នឹងទទួលបាននូវធាតុចូល និងការគាំទ្រពីសំណាក់ក្រុមការងារបច្ចេកទេសចម្រុះស្តីពីសុខដុមនីយកម្ម និងភាពជាដៃគូ ។

១១- ខ្ញុំក៏សង្ឃឹមផងដែរថា យើងអាចពិនិត្យឡើងវិញអំពីដំណើរការនៃគណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ (GDCC) ដើម្បីធានាថា គ្រប់សកម្មភាពអាទិភាពទាំងអស់ ត្រូវបានអនុវត្តទាន់ពេលវេលា ។ ខ្ញុំក៏មានសុទិដ្ឋិនិយមថា កិច្ចប្រជុំនៃគណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍នាពេលខាងមុខ នឹងផ្តល់កាលានុវត្តភាពសម្រាប់ត្រួតពិនិត្យវឌ្ឍនភាពលើសកម្មភាពនានាដែលបានឯកភាពក្នុងវេទិកានេះ ក៏ដូចជាសូចនាករតាមដានត្រួតពិនិត្យរួមគ្នា និងកិច្ចខិតខំប្រឹងប្រែងក្នុងការធ្វើសមាហរណកម្មរវាងការងារផែនការ និងថវិកាផងដែរ ។

*លោកជំទាវ ឯកឧត្តម លោក លោកស្រី*

១២- ក្នុងស្មារតីនេះ ខ្ញុំសង្ឃឹមថា ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្នុងតួនាទីជាលេខាធិការដ្ឋាននៃគណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ ដែលមានភារកិច្ចសម្របសម្រួលហិរញ្ញប្បទានសហប្រតិបត្តិការ អាចផ្តល់ការគាំទ្រដល់ដំណើរការតាមវិស័យ ក្នុងសូចនាករតាមដានរួមគ្នា ក្នុងការគ្រប់គ្រងហិរញ្ញប្បទានសហប្រតិបត្តិការ និងក្នុងការអភិវឌ្ឍន៍សមត្ថភាព ក៏ដូចជាការគាំទ្រដល់ការពង្រឹងការតាមដានដែលនេះជាតួនាទីប្រគល់ដោយគណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ ។ បទពិសោធន៍ដែលទទួលបានពីការអនុវត្តន៍គំនិតផ្តួចផ្តើមមួយចំនួនកន្លងមក ដូចជា «ការបង្កើនប្រសិទ្ធភាពនៃភាពជាដៃគូ» និងការវាយតម្លៃសេចក្តីថ្លែងការណ៍ទីក្រុងប៉ារីស នាពេលថ្មីៗកន្លងមកនេះ បានបង្កើតមូលដ្ឋានគ្រឹះដ៏រឹងមាំ និងអាចផ្តល់ការណែនាំសម្រាប់គ្រប់ទិដ្ឋភាពការងាររបស់យើង ។

*ឯកឧត្តមប្រធាន លោកជំទាវ ឯកឧត្តម លោក លោកស្រី*

១៣- យើងមានបទពិសោធន៍ល្អៗជាច្រើន តាមរយៈកិច្ចខិតខំប្រឹងប្រែងរបស់យើងក្នុងការអនុវត្តន៍ក្របខ័ណ្ឌគោលនយោបាយស្តីពីប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការ និងការអភិវឌ្ឍន៍ដោយផ្តោតលើលទ្ធផលទាំងនៅកម្រិតជាតិ ទាំងនៅកម្រិតសកល ។ ខ្ញុំជឿជាក់ថា ទិសដៅកម្រិតគោលនយោបាយរបស់យើង ត្រូវបានរៀបចំដោយសម្រិតសម្រាំង ដែលឆ្លុះបញ្ចាំងអំពីស្ថានភាពជាក់ស្តែងរបស់កម្ពុជា និងដោយផ្តោតលើលទ្ធផល ។

១៤- យើងសម្រេចបានសមិទ្ធផលជាច្រើនដូចជាៈ

- ការយល់ដឹងអំពីគោលការណ៍នៃប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការ ត្រូវបានចាប់ផ្តើមអនុវត្តនៅកម្រិតវិស័យ ។
- រាជរដ្ឋាភិបាលបានបង្កើតក្របខ័ណ្ឌគោលនយោបាយដែលប្រទាក់ក្រឡាគ្នានៅតាមវិស័យសំខាន់ៗ សម្រាប់ដៃគូអភិវឌ្ឍន៍ផ្តល់ការគាំទ្រ ។

- ផែនការជាតិ- ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម- គឺជាក្របខ័ណ្ឌណែនាំសម្រាប់ការប្រើប្រាស់ធនធានក្រៅប្រទេស ហើយដៃគូអភិវឌ្ឍន៍បានតម្រឹមការគាំទ្ររបស់ខ្លួន ។ រីឯភាពអាចទស្សន៍ទាយទុកជាមុនក៏បានប្រសើរជាងមុន ។
- សូចនាករតាមដានរួមគ្នាត្រូវបានចាក់គ្រឹះតាមបណ្ដាវិស័យអាទិភាពនានា ។

១៤- ប៉ុន្តែ ទោះជាយ៉ាងនេះក្តី ក៏យើងមានការឯកភាពរួមគ្នា និងមានកាលានុវត្តភាពសម្រាប់អនុវត្តបន្ត ។
- សូចនាករតាមដានរួមគ្នាបានបញ្ជាក់អំពីទំនាក់ទំនងយ៉ាងច្បាស់លាស់ រវាងការសម្រេចបាននូវការអភិវឌ្ឍន៍ដោយផ្តោតលើលទ្ធផល ជាមួយនឹងសកម្មភាពដែលពាក់ព័ន្ធនឹងប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការ ។ នេះជាចំណុចចាប់ផ្តើមសម្រាប់ការសម្រួចផ្តល់ការគាំទ្ររបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា នៅពេលមានតម្រូវការ ។
- ការគាំទ្រការងារនៅកម្រិតវិស័យទាមទារឱ្យអនុវត្ត និងពង្រឹងការប្រើប្រាស់អភិក្រមគ្រប់គ្រងទូទាំងកម្មវិធី នៅក្នុងបរិការណ៍សមស្រប និងអាចអនុវត្តបាន ។
- កិច្ចការរបស់យើងស្តីពីការប្រើប្រាស់ប្រព័ន្ធជាតិ នឹងផ្តល់នូវចំណុចចាប់ផ្តើមល្អ សម្រាប់ធានាថាកំណែទម្រង់ស្នូលនានា រួមមានកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងកំណែទម្រង់រដ្ឋបាលសាធារណៈត្រូវបានអនុវត្ត ដើម្បីពង្រឹងសមត្ថភាពប្រកបដោយចីរភាព ។
- កិច្ចខិតខំប្រឹងប្រែងបច្ចុប្បន្នក្នុងការធ្វើសុខដុមនីយកម្មរវាងការងារផែនការនិងថវិកា ត្រូវអនុវត្តក្នុងបរិការណ៍នៃកំណែទម្រង់ទាំងនេះ នៅក្នុងការងារកម្រិតវិស័យ ។
- យន្តការនៃគណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ នឹងត្រូវប្រើប្រាស់សម្រាប់តាមដានសូចនាករតាមដានរួមគ្នា និងកំណែទម្រង់ស្នូល ដើម្បីធានាថាការអនុវត្តន៍មានវឌ្ឍនភាព ហើយបញ្ហារាំងស្ទះនានាត្រូវបានដោះស្រាយផ្អែកលើគោលការណ៍នៃភាពជាដៃគូ និងគណនេយ្យភាពទ្វេទិស ។

*លោកជំទាវ ឯកឧត្តម លោក លោកស្រី*

១៥- យើងត្រូវបន្តពង្រឹងវឌ្ឍនភាពបន្ថែម ហើយស្ថាប័នរបស់ខ្ញុំបានត្រៀមខ្លួនជាស្រេច សម្រាប់ផ្តល់ការគាំទ្រ និងសម្របសម្រួលកិច្ចខិតខំប្រឹងប្រែងទាំងនេះ ។ ខ្លឹមសារទាំងឡាយដែលខ្ញុំបានលើកឡើង ទាមទារឱ្យមានការសម្របសម្រួលនិងកិច្ចសហការរវាងបណ្ដាស្ថាប័ននៃរាជរដ្ឋាភិបាល និងរវាងបណ្ដាដៃគូអភិវឌ្ឍន៍ និងរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ ។ ដោយផ្តោតទៅលើផលប្រយោជន៍ដែលមានទាំងសងខាង ខ្ញុំមានជំនឿជឿជាក់ថា យើងអាចបង្កើនវឌ្ឍនភាពបន្ថែមទៀតក្នុងបណ្ដាឆ្នាំខាងមុខ ។

សូមអរគុណចំពោះការយកចិត្តទុកដាក់ស្តាប់